**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៨ . អនុក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# យន្តការ និងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៦៩អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និងការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញអនុក្រឹត្យលេខ៥៣អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ២០៩អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់យន្តការ និងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានលើការអភិរក្សជីវៈចម្រុះ បរិស្ថាន និងសុខភាពមនុស្ស
- ធានាប្រសិទ្ធភាពនៃការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព
- លើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើប និងទប់ស្កាត់ហានិភ័យបណ្តាលមកពី សារពាង្គកាយកែច្នៃរស់
- ការពារបរិស្ថាននិងសុខភាពមនុស្ស។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពីជីវសុវត្ថិភាព។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ៖

- **ការវាយតម្លៃហានិភ័យ** សំដៅដល់ការកំណត់ពីសក្តានុពលនៃហានិភ័យ ការប៉ាន់ប្រមាណពីលទ្ធភាពនៃហានិភ័យ ដែលអាចកើតឡើង និងពីការប៉ាន់ប្រមាណពីទំហំ នៃការខូចខាតដោយហានិភ័យ។
- **ការគ្រប់គ្រងហានិភ័យ** សំដៅដល់វិធីសម្រាប់បញ្ចៀស កាត់បន្ថយហានិភ័យដែលអត្តសញ្ញាណ និងសក្តានុពលត្រូវបានកំណត់រួចហើយ ឱ្យនៅត្រឹមកម្រិតមួយដែលអាចទទួលយកបាន។
- **ការខូចខាតលើសុខភាពមនុស្ស** សំដៅដល់ការបង្កឱ្យមានជំងឺ របួស ពិការ ឬស្លាប់។
- **ការខូចខាតលើបរិស្ថាន** សំដៅដល់ការខូចខាត ដែលនាំទៅដល់ការចំណាយលើការស្តារឡើងវិញ នៃបរិស្ថាន និងជីវៈចម្រុះឱ្យបានសមស្រប រួមទាំងការស្តារឡើងវិញនូវប្រភពដើមនៃជីវៈចម្រុះ។
- **ការខូចខាតលើការអភិរក្សជីវៈចម្រុះ** សំដៅដល់ការខូចខាតដែលនាំទៅដល់ការផ្លាស់ប្តូរជាច្រើនផ្នែកបរិមាណ និងគុណភាពភាវៈរស់នៃប្រភេទ នៅក្នុងប្រព័ន្ធអេកូឡូស៊ី។

- **ការខូចខាតលើការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព** សំដៅដល់ការធ្លាក់ចុះ ទាំងផ្នែកបរិមាណ ទាំងផ្នែកគុណភាពនៃសមាសភាពជីវៈចម្រុះ ដែលប៉ះពាល់ជាអវិជ្ជមានដល់ការប្រើប្រាស់បន្តបន្ទាប់នូវសមាសភាពទាំងនោះ ហើយនាំទៅរកការបាត់បង់សេដ្ឋកិច្ច ការបាត់បង់ប្រាក់ចំណូល ការរំខានដល់ការរស់នៅរបស់សហគមន៍ ឬការកាត់បន្ថយសិទ្ធិប្រើប្រាស់ជាសមូហភាព។
- **សារពាង្គកាយកែច្នៃរស់** សំដៅដល់សារពាង្គកាយរស់ដែលមានផ្ទុកនូវសារធាតុសេនេទិចថ្មី ទទួលយកតាមរយៈការប្រើប្រាស់ជីវៈបច្ចេកវិទ្យាទំនើប។

## ជំពូកទី២
## គណៈកម្មាធិការជាតិជីវសុវត្ថិភាព

**មាត្រា៥.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជីវសុវត្ថិភាព ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ជ.ស.**។

**មាត្រា៦.-**

**គ.ជ.ជ.ស.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១ រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១ រូប | សមាជិក |
| - អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១ រូប | សមាជិក |

សមាសភាពជាក់ស្តែង នៃ **គ.ជ.ជ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាជិក **គ.ជ.ជ.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ជ.ជ.ស.**។ របៀបបទនៃការប្រជុំត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ជ.ស.**។ **គ.ជ.ជ.ស.**ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន។

**មាត្រា៧.-**

**គ.ជ.ជ.ស.** មានតួនាទី និងភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រស្តីពីជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាលកម្ពុជានិងលេខាធិការដ្ឋាននៃអនុសញ្ញាស្តីពីជីវៈចម្រុះដើម្បីពង្រឹងការអនុវត្តពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព
- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលអំពីពិធីសារ និងសេចក្តីព្រាងអនុស្សរណៈនានា ដែលទាក់ទងនឹងការអនុវត្តពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព
- រៀបចំ ត្រួតពិនិត្យ និងឃ្លាំមើលការអនុវត្តផែនការសកម្មភាពស្តីពីជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើប
- ជំរុញការបញ្ជ្រាបគោលនយោបាយជីវសុវត្ថិភាព និងជីវបច្ចេកវិទ្យាទំនើបទៅក្នុងវិស័យពាក់ព័ន្ធ
- ឃ្លាំមើល និងវាយតម្លៃលើការបំពេញកាតព្វកិច្ចនៃពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព
- ជំរុញឱ្យមានការយល់ដឹងជាសាធារណៈ អំពីតម្រូវការរៀបចំក្របខណ្ឌជីវសុវត្ថិភាពជាតិ
- ត្រួតពិនិត្យ និងជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធលើបញ្ហាជីវសុវត្ថិភាព
- ធានាឱ្យក្របខណ្ឌជីវសុវត្ថិភាពជាតិស្របតាមគោលនយោបាយ ផ្នែកបរិស្ថានរបស់រាជរដ្ឋាភិបាល
- កែសម្រួល អនុម័ត និងវាយតម្លៃលើការរៀបចំក្របខណ្ឌជីវសុវត្ថិភាពជាតិ និងធានាអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់
- តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងពិនិត្យឡើងវិញនូវភាពចាំបាច់ជាអាទិភាព នៃផែនការយុទ្ធសាស្ត្រស្តីពីជីវសុវត្ថិភាពនិងជីវបច្ចេកវិទ្យាទំនើប រៀងរាល់ពីរឆ្នាំម្តង ដោយបញ្ចូលសកម្មភាពពាក់ព័ន្ធ
- ផ្តល់ការណែនាំ និងវាយតម្លៃលើគោលនយោបាយទូទៅ ក្នុងការអនុវត្តគម្រោងជាតិ និងលើលទ្ធផលគម្រោង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៨.-**

គ.ជ.ជ.ស. មានក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យ ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| - តំណាងក្រសួងបរិស្ថាន | ១ រូប | ប្រធាន |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | អនុប្រធាន |
| - តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ១ រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ១ រូប | សមាជិក |
| - តំណាងក្រសួងការពារជាតិ | ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១ រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | ១ រូប | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១ រូប | សមាជិក |
| - តំណាងក្រសួងធនធានទឹក និងឧតុនិយម | ១រូប | សមាជិក ។ |

សមាសភាពជាក់ស្តែង និងបែបបទនៃការប្រជុំនៃក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ជ.ស. ។

ក្នុងករណីចាំបាច់ប្រធាន គ.ជ.ជ.ស. អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត មកចូលរួមជាសមាជិក ។

**មាត្រា៩.-**

ក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ត្រួតពិនិត្យរកសារពាង្គកាយកែច្នៃរស់ដែលបានសាយភាយ ឬលេចធ្លាយពីការប្រើប្រាស់ ការដឹកជញ្ជូន និងធ្វើរបាយការណ៍ពីហានិភ័យ ឬហេតុការណ៍នេះ ព្រមទាំងលទ្ធផលនៃការខូចខាត
- ទទួលព័ត៌មាន និងចាត់វិធានការបន្ទាន់ នៅពេលណាដែលមានហេតុការណ៍លេចធ្លាយ ឬសាយភាយសារពាង្គកាយកែច្នៃរស់ដោយចៃដន្យ ដើម្បីទប់ស្កាត់ ឬកាត់បន្ថយទំហំនៃការខូចខាត ដល់ធនធានជីវៈចម្រុះ និងសុខភាពមនុស្ស
- បណ្តុះបណ្តាលដល់មន្ត្រីនៃស្ថាប័នពាក់ព័ន្ធពីបច្ចេកទេស វិធានការការពារ និងគ្រប់គ្រងការសាយភាយសារពាង្គកាយកែច្នៃរស់
- បំពេញការងារផ្សេងៗទៀត ដែល គ.ជ.ជ.ស. ប្រគល់ជូន ។

**មាត្រា១០.-**

ប្រធាន **គ.ជ.ជ.ស.** មានសិទ្ធិបញ្ជាផ្ទាល់ឱ្យក្រុមប្រតិបត្តិការគ្រប់គ្រងហានិភ័យ ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា ។

**មាត្រា១១.-**

**គ.ជ.ជ.ស.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងនៅក្រសួងបរិស្ថាន ។

លេខាធិការដ្ឋាន **គ.ជ.ជ.ស.** ត្រូវដឹកនាំដោយលេខាធិការមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយ លេខាធិការរងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា១២.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ជ.ជ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី៣
## ក្រុមវិទ្យាសាស្ត្រពិគ្រោះយោបល់

**មាត្រា១៣.-**

ត្រូវបានបង្កើតក្រុមវិទ្យាសាស្ត្រពិគ្រោះយោបល់ ដែលសរសេរជាអក្សរកាត់ថា **ក.វ.ព.យ.** ដែលមានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា១៤.-**

**ក.វ.ព.យ.** មានសមាសភាពជាអ្នកឯកទេសវិទ្យាសាស្ត្រដូចតទៅ ៖

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១ រូប ប្រធាន
- តំណាងក្រសួងបរិស្ថាន ១ រូប អនុប្រធាន
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប សមាជិក
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ១ រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ១ រូប សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប សមាជិក
- តំណាងរាជបណ្ឌិត្យសភាកម្ពុជា ១ រូប សមាជិក
- តំណាងសាកលវិទ្យាល័យពាក់ព័ន្ធ ១ រូប សមាជិក
- តំណាងមន្ទីរពិសោធន៍ពាក់ព័ន្ធ ១ រូប សមាជិក ។

សមាសភាពជាក់ស្តែងនៃ **ក.វ.ព.យ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

ក្នុងករណីចាំបាច់ **គ.ទ.ព.ឃ.** អាចស្នើសុំទៅក្រសួងបរិស្ថាន នូវអ្នកឯកទេសវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិបន្ថែមទៀត ដើម្បីជាជំនួយក្នុងការងាររបស់ខ្លួន។ ជំនាញបន្ថែមដែលស្នើសុំ មានជាអាទិ៍ អេកូឡូស៊ី វិទ្យាសាស្ត្រគ្រាប់ពូជ វិទ្យាសាស្ត្រខាងបំពុលបរិស្ថាន ការបង្កាត់ពូជសត្វ វីរុសវិទ្យា មីក្រុបវិទ្យា ជីវវិទ្យាម៉ូលេគុល ជីវបច្ចេកវិទ្យា សរីរវិទ្យា និងការបង្កាត់ពូជរុក្ខជាតិ។

**មាត្រា១៥.-**

**គ.ទ.ព.ឃ.** មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ពិនិត្យឯកសារវាយតម្លៃលើហានិភ័យ ដែលភ្ជាប់ជាមួយពាក្យស្នើសុំការឯកភាពជាមុន ក្នុងការនាំចូល និងនាំចេញសារពាង្គកាយកែច្នៃរស់ និងផ្តល់យោបល់ជូនក្រសួងបរិស្ថាន
- ពិនិត្យឯកសារបន្ថែមនៃការវាយតម្លៃហានិភ័យ ដែលក្រសួងបរិស្ថាន អាចស្នើឱ្យក្រុមអ្នកជំនាញការឯករាជ្យណាមួយធ្វើ
- រក្សាព័ត៌មានសម្ងាត់ដែលបានកំណត់ លើកអនុសាសន៍ជូនក្រសួងបរិស្ថាន ក្នុងការចាត់វិធានការរឹតបន្តឹង ការតាមដាន នីតិវិធីត្រួតពិនិត្យ ផ្តល់លក្ខខណ្ឌវិទ្យាសាស្ត្រសមស្រប
- លើកសំណើវិធានការគ្រប់គ្រងហានិភ័យ
- ជួយក្នុងការចងក្រងព័ត៌មានវិទ្យាសាស្ត្រ សម្រាប់សកម្មភាពលើកកម្ពស់ ការយល់ដឹងសាធារណៈ
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាល ឬក្រសួងបរិស្ថានប្រគល់ជូន។

**មាត្រា១៦.-**

លេខាធិការដ្ឋានរបស់ **គ.ជ.ជ.ស.** ជាសេនាធិការឱ្យ **គ.ទ.ព.ឃ.** ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៤
## នីតិវិធីស្នើសុំការនាំចូល
## និងប្រើប្រាស់សារពាង្គកាយកែច្នៃរស់

### ផ្នែកទី១
### ការនាំចូលដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់

**មាត្រា១៧.-**

ចំពោះការសុំនាំចូលនិងប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ម្ចាស់សំណើត្រូវដាក់ពាក្យស្នើសុំការឯកភាព

ជាមុន និងត្រូវដាក់រាល់ឯកសារសារពាង្គកាយកែច្នៃរស់ជូនក្រសួងបរិស្ថាន ដូចមានចែងក្នុងជំពូកទី៤ និងជំពូកទី៥នៃអនុក្រឹត្យនេះ។

រាល់ពាក្យស្នើសុំការឯកភាពជាមុន ត្រូវមានការបញ្ជាក់ឱ្យច្បាស់ពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានរៀបរាប់នៅក្នុងនោះ។

ម្ចាស់សំណើ អាចសុំដកវិញបាននូវពាក្យស្នើសុំការឯកភាពជាមុន នៅមុនពេលដែលក្រសួងបរិស្ថានចេញសេចក្តីសម្រេច។

**មាត្រា១៨.-**

ម្ចាស់សំណើ ត្រូវបង់កម្រៃរដ្ឋបាលសម្រាប់ការដាក់ពាក្យស្នើសុំនីមួយៗរបស់ខ្លួន នៅក្រសួងបរិស្ថាន។ ការបង់កម្រៃនេះត្រូវបានលើកលែង សម្រាប់ស្ថាប័នស្រាវជ្រាវរបស់រដ្ឋ។

កម្រៃរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ និងការចាត់ចែងកម្រៃរដ្ឋបាល ដែលទទួលបានត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា១៩.-**

ការនាំចូលជាលើកទីមួយ នូវសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ ត្រូវមានការវាយតម្លៃហានិភ័យ និងត្រូវស្នើសុំការឯកភាពជាមុនពីក្រសួងបរិស្ថាន មុនពេលស្នើសុំការអនុញ្ញាតនាំចូលពីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ។

ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ក្នុងព្រំដែនកំណត់ ត្រូវអនុវត្តតាមស្តង់ដារនិងគោលការណ៍បច្ចេកទេស ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រោយពីបានពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ។

**មាត្រា២០.-**

ម្ចាស់សំណើ ត្រូវដាក់ពាក្យស្នើសុំដូចមានចែងក្នុងមាត្រា១៩ខាងលើនេះ ដោយភ្ជាប់ជាមួយនូវឯកសារវាយតម្លៃហានិភ័យនៃសារពាង្គកាយកែច្នៃរស់ ដែលត្រូវបានស្នើនាំចូលនៅក្រសួងបរិស្ថាន ក្នុងរយៈពេលយ៉ាងតិច ៩០ (កៅសិប) ថ្ងៃ មុនកាលបរិច្ឆេទនៃគម្រោងនាំចូល។

ពាក្យស្នើសុំត្រូវរៀបរាប់ ៖

- ឈ្មោះម្ចាស់សំណើនិងព័ត៌មានសម្រាប់ទំនាក់ទំនង
- ទីតាំងសម្រាប់ធ្វើសកម្មភាពប្រើប្រាស់ក្នុងព្រំដែនកំណត់
- ប្រភេទ និងអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់ដែលត្រូវនាំចូល
- ប្រភេទ និងគោលបំណងនៃសកម្មភាព ដូចជាយកមកដើម្បីស្តុកទុក ដឹកជញ្ជូន ផលិតឡើងវិញ

ធ្វើការបណ្តុះ កែច្នៃ បំផ្លាញចោល បោះចោល ឬប្រើប្រាស់សារពាង្គកាយកែច្នៃរស់ទាំងនោះ ដើម្បីគោលបំណងផ្សេងទៀត

- សក្តានុពលនៃហានិភ័យ ដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ទាំងនោះ ឬពីសកម្មភាពដែលបម្រុងនឹងអនុវត្ត
- វិធានការសម្រាប់ជួសជុល ឬស្តារការខូចខាតឡើងវិញ ក្នុងករណីមានការធ្លាយចេញ ឬសាយភាយសារពាង្គកាយកែច្នៃរស់ ទៅក្នុងបរិស្ថានដោយសកម្មភាពរបស់ខ្លួន ។

**មាត្រា២១.-**

ក្រសួងបរិស្ថាន ដោយមានការពិគ្រោះយោបល់ជាមួយ **គ.ទ.ព.ឃ.** អាចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ តម្រូវឱ្យផ្តល់ព័ត៌មានបន្ថែមជាអាទិ៍ ឯកសារបន្ថែម ស្តីពីការវាយតម្លៃហានិភ័យ ។

ក្រសួងបរិស្ថាន អាចតម្រូវឱ្យម្ចាស់សំណើធ្វើការវាយតម្លៃហានិភ័យបន្ថែម ឬចាត់តាំងអ្នកជំនាញការឯករាជ្យផ្សេងទៀតធ្វើការវាយតម្លៃ ។ ការចំណាយចំពោះការវាយតម្លៃហានិភ័យ ជាបន្ទុករបស់ម្ចាស់សំណើ ។

ម្ចាស់សំណើត្រូវឆ្លើយតបចំពោះតម្រូវការព័ត៌មានបន្ថែម ដូចមានចែងខាងលើនេះ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃទទួលបានដំណឹងអំពីតម្រូវការនេះ ដោយបញ្ជូនឯកសារព័ត៌មានបន្ថែមទៅក្រសួងបរិស្ថាន ។ ក្នុងករណីដែលម្ចាស់សំណើ ពុំអាចឆ្លើយតបក្នុងរយៈពេលកំណត់ខាងដើម ម្ចាស់សំណើអាចសុំពន្យារពេលតាមការកំណត់របស់ក្រសួងបរិស្ថាន ។

ប្រសិនបើ ម្ចាស់សំណើពុំបានឆ្លើយតបក្នុងរយៈពេលកំណត់នេះទេ ក្រសួងបរិស្ថានត្រូវជូនដំណឹងទៅម្ចាស់សំណើ ពីការបដិសេធសំណើសុំការឯកភាពជាមុន ដើម្បីនាំចូលសារពាង្គកាយកែច្នៃរស់ សម្រាប់ប្រើប្រាស់ក្នុងព្រំដែនកំណត់ ។

ប្រសិនបើ ម្ចាស់សំណើបានបញ្ជូនព័ត៌មានបន្ថែមដែលបានតម្រូវឱ្យផ្តល់ត្រឹមត្រូវ តាមពេលកំណត់ក្រសួងបរិស្ថានត្រូវបញ្ជូនព័ត៌មាននេះទៅ **គ.ទ.ព.ឃ.** ។ **គ.ទ.ព.ឃ.** ត្រូវដាក់ជូនក្រសួងបរិស្ថាននូវរបាយការណ៍ និងផ្តល់យោបល់ ដើម្បីចាត់ការចំពោះពាក្យស្នើសុំ ។

ក្រោយពេលពិនិត្យរបាយការណ៍ និងផ្តល់យោបល់របស់ **គ.ទ.ព.ឃ.** ក្រសួងបរិស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ទៅម្ចាស់សំណើនិងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពជាតិ ដោយបញ្ជាក់ពី ៖

- ការឯកភាពឱ្យដាក់ពាក្យស្នើសុំការអនុញ្ញាតដោយមាន ឬគ្មានលក្ខខណ្ឌ និងបញ្ជាក់អំពីការឯកភាពចំពោះការនាំចូលបន្តបន្ទាប់មកទៀត នូវសារពាង្គកាយកែច្នៃរស់ដដែលនេះ ឬ
- ការបដិសេធសំណើនាំចូល ។

**មាត្រា២២.-**

ក្នុងការផ្តល់ការឯកភាពជាមុន ក្រសួងបរិស្ថាន តម្រូវឱ្យម្ចាស់សំណើដាក់នូវវិធានការគ្រប់គ្រងហានិភ័យ ស្លាកសញ្ញា និងលក្ខខណ្ឌចាំបាច់ចំពោះសកម្មភាពក្នុងការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ក្នុងព្រំដែនកំណត់។ វិធានការគ្រប់គ្រងហានិភ័យការដាក់ស្លាកសញ្ញា និងតម្រូវការផ្សេងៗទៀតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ នៅពេលទទួលបានការឯកភាពជាមុន ម្ចាស់សំណើត្រូវភ្ជាប់ច្បាប់ដើមនៃលិខិតឯកភាពជាមុនជាមួយពាក្យស្នើសុំការអនុញ្ញាត ដែលត្រូវដាក់ជូនជាបន្តទៅស្ថាប័នមានសមត្ថកិច្ច ក្នុងការចេញលិខិតអនុញ្ញាត។

**មាត្រា២៣.-**

ករណីបដិសេធពាក្យស្នើសុំ ក្រសួងបរិស្ថានត្រូវបញ្ជាក់ពីមូលហេតុជូនទៅម្ចាស់សំណើ។

## ផ្នែកទី២

## ការនាំចូលដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា

**មាត្រា២៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានគោលបំណងនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ទៅក្រសួងបរិស្ថានអំពីគោលបំណងនៃការស្នើសុំការនាំចូលរបស់ខ្លួន ដើម្បីសុំការឯកភាពជាមុន ។

**មាត្រា២៥.-**

ម្ចាស់សំណើ ត្រូវរៀបរាប់នៅក្នុងសេចក្តីជូនដំណឹង ពីការស្នើសុំនាំចូលសារពាង្គកាយកែច្នៃរស់របស់ខ្លួននូវ៖

- ព័ត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ
- ការវាយតម្លៃហានិភ័យ ស្របតាមការណែនាំក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ និង
- ព័ត៌មានបន្ថែមដែលម្ចាស់សំណើយល់ថាទាក់ទងនឹងការវាយតម្លៃសក្តានុពលលើហានិភ័យ និង/ឬមានប្រយោជន៍សម្រាប់សំណើរបស់ខ្លួន។

**មាត្រា២៦.-**

ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងជាមុន ក្រសួងបរិស្ថានត្រូវឆ្លើយតបទៅម្ចាស់សំណើវិញ ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់៖

- កាលបរិច្ឆេទនៃការទទួលបានសេចក្តីជូនដំណឹង

- ព័ត៌មានបន្ថែម ដែលតម្រូវឱ្យម្ចាស់សំណើផ្តល់នូវការដាក់ពាក្យសុំរបស់ខ្លួន ដែលក្នុងនោះក្រសួងបរិស្ថានតម្រូវឱ្យម្ចាស់សំណើផ្តល់ក្នុងការវាយតម្លៃបន្ថែមលើហានិភ័យ។ ចំពោះការវាយតម្លៃបន្ថែមនេះ ក្រសួងបរិស្ថានអាចតម្រូវឱ្យម្ចាស់សំណើ ឬអ្នកជំនាញការឯករាជ្យណាមួយធ្វើក៏បាន។ ការចំណាយលើការវាយតម្លៃបន្ថែមលើហានិភ័យនេះ ជាបន្ទុករបស់ម្ចាស់សំណើ។

**មាត្រា២៧.-**

ម្ចាស់សំណើ ត្រូវឆ្លើយតបចំពោះតម្រូវការព័ត៌មានបន្ថែម ដូចមានចែងក្នុងគំនូសទី២ មាត្រា២៦ ខាងលើនេះ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃទទួលបានតម្រូវការនេះដោយបញ្ជូនឯកសារព័ត៌មានបន្ថែមទៅក្រសួងបរិស្ថាន។

ប្រសិនបើ ម្ចាស់សំណើត្រូវធ្វើការកែតម្រូវឯកសារពាក្យសុំឡើងវិញនោះ ម្ចាស់សំណើត្រូវបញ្ជូនឯកសារនេះទៅក្រសួងបរិស្ថាន ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ។

ប្រសិនបើ ម្ចាស់សំណើពុំបានឆ្លើយតបក្នុងរយៈពេលដែលបានកំណត់នេះទេ សេចក្តីជូនដំណឹងពីការស្នើសុំនាំចូលត្រូវចាត់ទុកជាមោឃៈ។

ប្រសិនបើ ម្ចាស់សំណើបានបញ្ជូនព័ត៌មានបន្ថែម ដែលតម្រូវឱ្យផ្តល់ត្រឹមត្រូវតាមពេលកំណត់ ក្រសួងបរិស្ថានត្រូវជូនដំណឹងទៅម្ចាស់សំណើពីការទទួលព័ត៌មានបន្ថែមនេះ ហើយត្រូវបញ្ជូនព័ត៌មាននេះទៅ **គ.ទ.ព.ឃ.**។

ក្នុងរយៈពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ គិតពីថ្ងៃទទួលបានសេចក្តីជូនដំណឹងពីការស្នើសុំនាំចូលឬក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតពីថ្ងៃទទួលបានព័ត៌មានបន្ថែម **គ.ទ.ព.ឃ.** ត្រូវដាក់ជូនក្រសួងបរិស្ថាននូវរបាយការណ៍ និងយោបល់ដើម្បីឱ្យម្ចាស់សំណើអនុវត្ត។ ក្រោយពេលទទួលបានរបាយការណ៍របស់ **គ.ទ.ព.ឃ.** ក្រសួងបរិស្ថានត្រូវផ្ញើរបាយការណ៍នេះទៅម្ចាស់សំណើ។ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ម្ចាស់សំណើអាចផ្តល់យោបល់របស់ខ្លួនលើរបាយការណ៍របស់ **គ.ទ.ព.ឃ.** ជូនទៅក្រសួងបរិស្ថានវិញ។ ក្រសួងបរិស្ថានត្រូវពិនិត្យយោបល់របស់ម្ចាស់សំណើ ក្នុងការធ្វើសេចក្តីសម្រេចការឯកភាពជាមុន។

ក្នុងរយៈពេល២៧០(ពីររយចិតសិប)ថ្ងៃ គិតពីថ្ងៃទទួលបានការជូនដំណឹងពីការស្នើសុំនាំចូល ឬទទួលបានព័ត៌មានដែលបានតម្រូវឱ្យផ្តល់បន្ថែម និង/ឬយោបល់លើរបាយការណ៍របស់ **គ.ទ.ព.ឃ.** ក្រសួងបរិស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីសេចក្តីសម្រេចរបស់ខ្លួនទៅម្ចាស់សំណើ និងទៅបណ្តាញផ្សព្វផ្សាយព័ត៌មាន ជីវសុវត្ថិភាពជាតិ ដោយបញ្ជាក់ពីៈ

- ការឯកភាពឱ្យដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូល ដោយមាន ឬគ្មានលក្ខខណ្ឌ និងបញ្ជាក់ពីការឯកភាពចំពោះការនាំចូលបន្តបន្ទាប់មកទៀត នូវសារពាង្គកាយកែច្នៃរស់ដដែលនេះ ឬ
- ការបដិសេធសំណើនាំចូល។

**មាត្រា២៨.-**

ក្នុងការផ្តល់ការឯកភាពជាមុន ចំពោះសំណើសុំនាំចូលសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ក្រសួងបរិស្ថាន តម្រូវឱ្យម្ចាស់សំណើដាក់វិធានការគ្រប់គ្រងហានិភ័យ ស្លាកសញ្ញា និង/ឬលក្ខខណ្ឌចំពោះសកម្មភាពប្រើប្រាស់សារពាង្គកាយកែច្នៃរស់ដែលបានស្នើនេះ។ វិធានការគ្រប់គ្រងហានិភ័យ ការដាក់ស្លាកសញ្ញា និងតម្រូវការមួយចំនួនទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

នៅពេលទទួលបានការឯកភាពជាមុន ម្ចាស់សំណើត្រូវភ្ជាប់ច្បាប់ដើមនូវលិខិតឯកភាពជាមុន ជាមួយពាក្យស្នើសុំការអនុញ្ញាត ដែលត្រូវដាក់ជូនស្ថាប័នមានសមត្ថកិច្ច។

ក្នុងករណីបដិសេធពាក្យស្នើសុំ ក្រសួងបរិស្ថាន ត្រូវបញ្ជាក់ពីមូលហេតុជូនទៅម្ចាស់សំណើ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពេលបានទទួលលិខិតបដិសេធការឯកភាពជាមុន ម្ចាស់សំណើអាចស្នើទៅក្រសួងបរិស្ថានឱ្យពិនិត្យសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ ដោយផ្អែកលើព័ត៌មានថ្មីៗដែលពុំទាន់បានរកឃើញនៅឡើយ នៅពេលដែលក្រសួងបរិស្ថានកំពុងធ្វើការសម្រេចលើពាក្យស្នើសុំនោះ។ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រសួងបរិស្ថានត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ ពីមូលហេតុដែលក្រសួងបរិស្ថានត្រូវរក្សាទុកសេចក្តីសម្រេចពីមុនរបស់ខ្លួន ក្នុងការបដិសេធ ឬពីការសម្រេចឯកភាពវិញ។

## ផ្នែកទី៣

## ការនាំចូលដើម្បីប្រើប្រាស់ផ្ទាល់ទៅក្នុងម្ហូបអាហារ ចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃ

**មាត្រា២៩.-**

ការនាំចូលសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ជាលើកទីមួយ ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬដើម្បីកែច្នៃ ត្រូវឱ្យមានការវាយតម្លៃហានិភ័យ ព្រមទាំងមានការឯកភាពពីក្រសួងបរិស្ថានជាមុន មុនពេលស្នើសុំការអនុញ្ញាតនាំចូល ពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៣០.-**

ម្ចាស់សំណើ ត្រូវរៀបរាប់នៅក្នុងពាក្យស្នើសុំការអនុញ្ញាតនាំចូលរបស់ខ្លួននូវ៖

- ព័ត៌មានដូចបានចែងនៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ
- ការវាយតម្លៃហានិភ័យស្របតាមការណែនាំ ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ និង
- ព័ត៌មានបន្ថែមដែលម្ចាស់សំណើយល់ថា ទាក់ទងនឹងការវាយតម្លៃសក្តានុពលនៃហានិភ័យ និង/ឬមានប្រយោជន៍សម្រាប់សំណើប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬដើម្បីកែច្នៃ។

**មាត្រា៣១.-**

ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យស្នើសុំការអនុញ្ញាតនាំចូល ក្រសួងបរិស្ថានត្រូវឆ្លើយតបទៅម្ចាស់សំណើវិញ ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ ៖

- កាលបរិច្ឆេទនៃការទទួលបានពាក្យស្នើសុំការឯកភាពជាមុន
- ព័ត៌មានបន្ថែមដែលតម្រូវឱ្យផ្តល់ក្នុងការដាក់ពាក្យសុំ ដែលក្នុងនោះក្រសួងបរិស្ថានអាចតម្រូវឱ្យមានការវាយតម្លៃបន្ថែមលើហានិភ័យ ដែលការវាយតម្លៃបន្ថែមនេះ ត្រូវធ្វើដោយម្ចាស់សំណើ ឬអ្នកជំនាញការឯករាជ្យណាមួយតាមការតម្រូវរបស់ក្រសួងបរិស្ថាន ហើយការចំណាយលើការវាយតម្លៃបន្ថែមលើហានិភ័យ ជាបន្ទុករបស់ម្ចាស់សំណើ ។

**មាត្រា៣២.-**

ម្ចាស់សំណើ ត្រូវឆ្លើយតបចំពោះតម្រូវការព័ត៌មានបន្ថែម ដូចមានចែងក្នុងមាត្រា៣១ខាងលើនេះ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលទទួលបានតម្រូវការ ដោយបញ្ជូនឯកសារព័ត៌មានបន្ថែមទាំងនោះទៅក្រសួងបរិស្ថាន ។

ប្រសិនបើ ម្ចាស់សំណើត្រូវធ្វើការកែតម្រូវឡើងវិញ នូវឯកសារ ឬព័ត៌មានណាមួយ នៅក្នុងពាក្យស្នើសុំនោះ ម្ចាស់សំណើ ត្រូវបញ្ជូនឯកសារ ឬព័ត៌មានទាំងនោះទៅក្រសួងបរិស្ថាន ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ។

ប្រសិនបើ ម្ចាស់សំណើពុំបានឆ្លើយតបចំពោះតម្រូវការព័ត៌មានបន្ថែម ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ដូចកាលកំណត់នេះទេ ក្រសួងបរិស្ថាន អាចធ្វើការបដិសេធសំណើសុំនាំចូល ហើយត្រូវជូនដំណឹងទៅម្ចាស់សំណើវិញ ពីការបដិសេធនេះ ។

ប្រសិនបើ ម្ចាស់សំណើបានបញ្ជូនព័ត៌មានបន្ថែមដែលបានតម្រូវឱ្យផ្តល់ត្រឹមត្រូវ តាមពេលកំណត់ក្រសួងបរិស្ថាន ត្រូវបញ្ជូនព័ត៌មាននេះទៅ **គ.ទ.ជ.ឃ.** ។

**គ.ទ.ជ.ឃ.** ត្រូវដាក់ជូនក្រសួងបរិស្ថានវិញនូវរបាយការណ៍ និងយោបល់របស់ខ្លួន ដើម្បីពិចារណានិងធ្វើការសម្រេចចំពោះពាក្យស្នើសុំ ។

ក្រោយពីបានពិនិត្យយោបល់ និងរបាយការណ៍របស់ **គ.ទ.ជ.ឃ.** ក្រសួងបរិស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីការសម្រេចរបស់ខ្លួនទៅម្ចាស់សំណើ និងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពជាតិ ដោយបញ្ជាក់ពី៖

- ការឯកភាពឱ្យដាក់ពាក្យស្នើសុំការអនុញ្ញាតដោយមាន ឬគ្មានលក្ខខណ្ឌ និងបញ្ជាក់អំពីការឯកភាព ចំពោះការនាំចូលបន្តបន្ទាប់មកទៀតនូវសារពាង្គកាយកែច្នៃរស់ដដែលនេះ ឬ
- ការបដិសេធសំណើនាំចូល ។

**មាត្រា៣៣.-**

ក្នុងការផ្តល់ការឯកភាពជាមុន ចំពោះសំណើសុំការអនុញ្ញាតនាំចូលសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬដើម្បីកែច្នៃ ដូចមានចែងក្នុងអនុក្រឹត្យនេះ ក្រសួងបរិស្ថានតម្រូវឱ្យដាក់វិធានការគ្រប់គ្រងហានិភ័យ ស្លាកសញ្ញា ឬតម្រូវការមួយចំនួនទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ នៅពេលទទួលបានការឯកភាពជាមុន ម្ចាស់សំណើត្រូវភ្ជាប់ច្បាប់ដើមនៃលិខិតឯកភាពជាមុន ជាមួយពាក្យស្នើសុំការអនុញ្ញាត ដែលត្រូវដាក់ជូនស្ថាប័នមានសមត្ថកិច្ច។

ក្នុងករណីបដិសេធពាក្យស្នើសុំ ក្រសួងបរិស្ថាន ត្រូវរៀបរាប់ពីមូលហេតុដែលពុំអាចផ្តល់ការឯកភាព។

**មាត្រា៣៤.-**

ក្នុងករណីដែលក្រសួងបរិស្ថានផ្តល់ការឯកភាពជាមុន ចំពោះការនាំចូលសារពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬដើម្បីកែច្នៃនោះ ក្រសួងបរិស្ថាន ត្រូវជូនដំណឹងទៅសមាជិកដទៃទៀតនៃពិធីសារកាតាហ្សេណាតាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ។ ព័ត៌មានទាំងនេះ ត្រូវរៀបរាប់ដោយសង្ខេបអំពីព័ត៌មាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃ អនុក្រឹត្យនេះ។

**មាត្រា៣៥.-**

ការដាំដុះសារពាង្គកាយកែច្នៃរស់ ទោះបីយកមកធ្វើការពិសោធ ការសាកល្បង ការប្រើប្រាស់ដើម្បីគោលបំណងណាមួយក្តី ធ្វើជាពូជដំណាំកែច្នៃក្តី ត្រូវអនុវត្តតាមស្តង់ដារ និងគោលការណ៍បច្ចេកទេសដោយយោងទៅតាមករណីជាក់ស្តែងមួយករណីម្តងៗ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

ការចិញ្ចឹមសារពាង្គកាយកែច្នៃរស់ ទោះបីយកមកធ្វើការពិសោធ ការសាកល្បង ការប្រើប្រាស់ដើម្បីគោលបំណងណាមួយក្តី ធ្វើជាពូជសត្វក្តី ត្រូវអនុវត្តតាមស្តង់ដារ និងគោលការណ៍បច្ចេកទេស ដោយយោងទៅតាមករណីជាក់ស្តែងមួយករណីម្តងៗ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៣៦.-**

រាល់ការបដិសេធសំណើនាំចូលទាំងឡាយដោយក្រសួងបរិស្ថាន ដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ ម្ចាស់សំណើ មានសិទ្ធិប្តឹងតវ៉ាតាមនីតិវិធីច្បាប់ជាធរមាន។

## ជំពូកទី៥
## ការវាយតម្លៃហានិភ័យ

**មាត្រា៣៧.-**

ការវាយតម្លៃហានិភ័យ ត្រូវអនុវត្តតាមលក្ខណៈវិទ្យាសាស្ត្រត្រឹមត្រូវស្របតាមខ្លឹមសារណែនាំ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ព្រមទាំងមានការទទួលស្គាល់ផ្នែកបច្ចេកទេសពាក់ព័ន្ធផងដែរ ។

ការវាយតម្លៃហានិភ័យ ត្រូវផ្អែកលើព័ត៌មានដែលបានរៀបរាប់នៅក្នុងពាក្យស្នើសុំ និងផ្អែកលើភស្តុតាងវិទ្យាសាស្ត្រផ្សេងទៀត ដែលអាចរកបាន ។

ក្រសួងបរិស្ថានដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចេញប្រកាសកំណត់លម្អិតអំពីប៉ារ៉ាម៉ែត្រ សម្រាប់ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ ។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការពិនិត្យឯកសារវាយតម្លៃហានិភ័យ ដែលម្ចាស់សំណើបានដាក់ជូន និងតម្រូវឱ្យមានការវាយតម្លៃហានិភ័យបន្ថែមទៀត ក្នុងករណីចាំបាច់ដោយឈរលើមូលដ្ឋាន មួយករណីម្តងៗ ។

**គ.ទ.ព.ឃ.** ត្រូវធ្វើការវាយតម្លៃហានិភ័យ ដោយផ្តោតការយកចិត្តទុកដាក់លើវិធានការគ្រប់គ្រងហានិភ័យ ដែលម្ចាស់សំណើបានស្នើឡើង និងវិធានការគ្រប់គ្រងហានិភ័យផ្សេងទៀត ដែលជាការចាំបាច់ក្នុងការកាត់បន្ថយហានិភ័យ ។

**មាត្រា៣៩.-**

ម្ចាស់សំណើ ត្រូវមានវិធានការគ្រប់គ្រងហានិភ័យដូចខាងក្រោមៈ

- ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ
- ផែនការសម្រាប់វិធានការគ្រាមានអាសន្នដោយចៃដន្យ
- ការបង្កើតយន្តការផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យសុវត្ថិភាព
- វិធានការដើម្បីទប់ស្កាត់ជាមុននូវការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាន ការសាយភាយដោយអចេតនាព្រមទាំងមានវិធានការដោះស្រាយ និងកាត់បន្ថយហានិភ័យទៅលើជីវៈចម្រុះ និងសុខភាពមនុស្សនៅពេលណាដែលហេតុការណ៍នេះកើតមានឡើង
- រាយការណ៍ជាបន្ទាន់ទៅក្រសួងបរិស្ថាន នៅពេលណាដែលអ្នកធ្វើសកម្មភាពទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដែលបានដឹងអំពីព័ត៌មានវិទ្យាសាស្ត្រថ្មីៗដែលបញ្ជាក់ថាសកម្មភាព...

ឬប្រតិបត្តិការ សារពាង្គកាយកែច្នៃរស់របស់ខ្លួន នោះអាចបណ្តាលឱ្យមានការប៉ះពាល់ជាអវិជ្ជមានដល់ការអភិរក្ស និងដល់ការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាពក្នុងបរិស្ថាន និងដល់សុខភាពមនុស្ស។

**មាត្រា៤០.-**

ក្នុងការពិនិត្យឯកសារវាយតម្លៃហានិភ័យ ឬឯកសារវាយតម្លៃហានិភ័យបន្ថែម គ.ទ.ព.យ. ត្រូវផ្តល់របាយការណ៍ជូនក្រសួងបរិស្ថាន ដោយភ្ជាប់យោបល់ស្តីពីវិធានការសម្រាប់សំណើសុំការឯកភាពជាមុននីមួយៗ ដូចជាវិធានការគ្រប់គ្រងហានិភ័យ ការបិទស្លាកសញ្ញា ឬបង្ហាញពីតម្រូវការទាំងឡាយ និង/ឬលក្ខខណ្ឌដែលត្រូវអនុវត្ត ដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់សារពាង្គកាយកែច្នៃរស់។

ខ្លឹមសាររបាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវសង្ខេបលទ្ធផលនៃការពិនិត្យឯកសារវាយតម្លៃហានិភ័យ សម្រាប់សំណើសុំការឯកភាពនីមួយៗ និងយោបល់ដែលតម្រូវឱ្យមានយុទ្ធសាស្ត្រ គ្រប់គ្រងហានិភ័យ ក៏ប៉ុន្តែពុំត្រូវរៀបរាប់អំពីព័ត៌មានសម្ងាត់ដែលត្រូវបានការពារ ដូចមានចែងក្នុងជំពូកទី៧ នៃច្បាប់ស្តីពីជីវសុវត្ថិភាព និងជំពូកទី៧ នៃអនុក្រឹត្យនេះ។

## ជំពូកទី៦

## ការនាំចេញសារពាង្គកាយកែច្នៃរស់

**មាត្រា៤១.-**

រាល់ការនាំចេញសារពាង្គកាយកែច្នៃរស់ ពីព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមជំពូកទី៤ នៃច្បាប់ស្តីពីជីវសុវត្ថិភាព។

**មាត្រា៤២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងនាំចេញពីព្រះរាជាណាចក្រកម្ពុជា នូវសារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិដោយច្បាប់ស្តីពីជីវសុវត្ថិភាព ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ទៅស្ថាប័នមានសមត្ថកិច្ចនៃប្រទេសដែលនាំចូល មុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤៣.-**

សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ទៅស្ថាប័នមានសមត្ថកិច្ចនៃប្រទេសដែលនាំចូលត្រូវរៀបរាប់ព័ត៌មានចាំបាច់ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

ព័ត៌មានដែលបានរៀបរាប់នៅក្នុងសេចក្ដីជូនដំណឹង ដូចបានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវមានការបញ្ជាក់បន្ថែមពីក្រសួងបរិស្ថាន អំពីភាពត្រឹមត្រូវនៃព័ត៌មានទាំងនោះ ។

**មាត្រា៤៤.-**

នីតិវិធីលម្អិតសម្រាប់ការនាំចេញ នូវសារពាង្គកាយកែច្នៃរស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

## ជំពូកទី៧
## ព័ត៌មានសម្ងាត់

**មាត្រា៤៥.-**

ក្រសួងបរិស្ថាន ត្រូវអនុញ្ញាតឱ្យម្ចាស់សំណើផ្ដល់ព័ត៌មានមួយចំនួន ដែលម្ចាស់សំណើចាត់ទុកថា ជាព័ត៌មានសម្ងាត់ មានជាអាទិ៍ ព័ត៌មាននៅក្នុងលិខិតជូនដំណឹង ឬនៅក្នុងសំណុំឯកសារនៃពាក្យស្នើសុំការអនុញ្ញាតនាំចូលសារពាង្គកាយកែច្នៃរស់ ដើម្បីធានារក្សាការសម្ងាត់ ។

ក្នុងករណីដូចមានចែងខាងលើនេះ ក្រសួងបរិស្ថាន មានសិទ្ធិធ្វើការសម្រេចយល់ព្រម ឬមិនយល់ព្រមចាត់ទុកថា ជាព័ត៌មានសម្ងាត់ ដែលម្ចាស់សំណើបានស្នើ ដោយផ្ដល់នូវមូលហេតុសមស្របទៅឱ្យម្ចាស់សំណើវិញ ។

ព័ត៌មានសម្ងាត់ គឺជាព័ត៌មានដែលមិនអាចយកមកលាតត្រដាងដោយគ្មានការអនុញ្ញាត ។
ព័ត៌មានដែលអាចចាត់ទុកថា ជាព័ត៌មានសម្ងាត់បាន លុះត្រាតែព័ត៌មាននោះមានលក្ខណៈដូចខាងក្រោម ៖

- ព័ត៌មានដែលត្រូវលាក់មិនឱ្យនរណាដឹង ទោះជាបុគ្គលនោះធ្វើការជាមួយប្រភេទព័ត៌មាននោះក៏ដោយ
- ព័ត៌មានដែលមានតម្លៃពាណិជ្ជកម្ម
- ព័ត៌មានដែលម្ចាស់សំណើត្រូវតែចាត់វិធានការសមស្របដើម្បីរក្សាការពារ ។

**មាត្រា៤៦.-**

ម្ចាស់សំណើ ត្រូវបែងចែកសំណុំឯកសារដែលជាព័ត៌មានសម្ងាត់ដាច់ដោយឡែក នៅលើផ្នែកណាមួយនៃទំព័រសំណុំឯកសារ នៃពាក្យស្នើសុំដោយសរសេរនូវពាក្យ ការសម្ងាត់ពាណិជ្ជកម្ម ។

ព័ត៌មានសម្ងាត់ ត្រូវបិទជិតដាក់នៅក្នុងស្រោមសំបុត្រដោយឡែក ដែលនឹងត្រូវបើកដោយប្រធានលេខាធិការដ្ឋាននៃ គ.ជ.ជ.ស. ដែលជាអ្នកទទួលខុសត្រូវក្នុងការរក្សាការសម្ងាត់ ។

**មាត្រា៤៧.-**

ទោះជាព័ត៌មានដែលក្រសួងបរិស្ថានបានបដិសេធការចាត់ទុកជាព័ត៌មានសម្ងាត់ក៏ដោយ មុននឹងត្រូវ

បរិស្ថានធ្វើការផ្សព្វផ្សាយព័ត៌មាននោះជាសាធារណៈ ក្រសួងបរិស្ថានត្រូវផ្តល់មូលហេតុ និងផ្តល់ឱកាសដល់ម្ចាស់សំណើដើម្បីពិគ្រោះយោបល់សិន ។

**មាត្រា៤៨.-**

**ក.ទ.ព.ឃ.** មានសិទ្ធិដឹងពីព័ត៌មានសម្ងាត់ទាំងអស់នេះ សម្រាប់ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ ។

**មាត្រា៤៩.-**

ក្នុងករណីដែលម្ចាស់សំណើសុំដក ឬបានដកពាក្យស្នើសុំការអនុញ្ញាត នាំចូលសារពាង្គកាយកែច្នៃសរីរាង្គក្រសួងបរិស្ថាន ត្រូវបន្តរក្សាការសម្ងាត់នៃព័ត៌មានដែលបានស្នើសុំជាព័ត៌មានសម្ងាត់ ទោះជាព័ត៌មាននោះក្រសួងបរិស្ថានបានយល់ព្រមចាត់ទុកជាព័ត៌មានសម្ងាត់ ឬពុំបានយល់ព្រមក៏ដោយ ។

**មាត្រា៥០.-**

ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធមិនត្រូវប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានសម្ងាត់ទាំងនោះ សម្រាប់សកម្មភាពពាណិជ្ជកម្ម ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីម្ចាស់សំណើឡើយ ។

**មាត្រា៥១.-**

ដោយមិននិយាយយោងដល់មាត្រា៥០ ខាងលើ ព័ត៌មានមួយចំនួនដូចខាងក្រោមនេះ មិនត្រូវចាត់ទុកជាព័ត៌មានសម្ងាត់ឡើយ ៖

- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់សំណើ
- ការរៀបរាប់ជាលក្ខណៈទូទៅនៃសារពាង្គកាយកែច្នៃរស់
- របាយការណ៍សង្ខេបនៃការវាយតម្លៃហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ដល់បរិស្ថាន និងដល់សុខភាពមនុស្ស និង
- ការរៀបរាប់ពីវិធីសាស្ត្រ និងផែនការឆ្លើយតបបន្ទាន់សម្រាប់គ្រោះមានអាសន្ន ឬការសាយភាយដោយចៃដន្យនៃសារពាង្គកាយកែច្នៃរស់ ។

**មាត្រា៥២.-**

ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាធារណជនមានសិទ្ធិដឹងពីហានិភ័យនៃសារពាង្គកាយកែច្នៃរស់ ។

## ជំពូកទី៨
## ប្រតិបត្តិការគ្រប់គ្រងហានិភ័យ

**មាត្រា៥៣.-**

នៅពេលដែលមានហេតុការណ៍ លេចធ្លាយ ឬសាយភាយសារពាង្គកាយកែច្នៃរស់ ដោយចៃដន្យកើតមានឡើង ម្ចាស់ឬអ្នកទទួលខុសត្រូវគ្រប់មធ្យោបាយដឹកជញ្ជូន ឬទីកន្លែងដែលហេតុការណ៍បានកើតឡើងត្រូវរាយការណ៍ជាបន្ទាន់ តាមមធ្យោបាយដ៏លឿនបំផុតទៅក្រសួងបរិស្ថាន។

**មាត្រា៥៤.-**

ក្នុងករណីដែលទទួលបានព័ត៌មានអំពីហេតុការណ៍ ដែលកើតឡើងជាយថាហេតុ ដែលបណ្តាលមកពីសកម្មភាពសារពាង្គកាយកែច្នៃរស់ ប្រធាន **គ.ជ.ជ.ស.** ត្រូវចាត់វិធានការណ៍ជាបន្ទាន់ ដើម្បីទប់ស្កាត់ហានិភ័យ ឬ គ្រោះថ្នាក់ ឬការខូចខាតដល់ធនធានជីវៈចម្រុះ និង/ឬសុខភាពមនុស្ស។

**មាត្រា៥៥.-**

ទន្ទឹមនឹងភារកិច្ចចាត់វិធានការឆ្លើយតបបន្ទាន់ ប្រធាន **គ.ជ.ជ.ស.** ត្រូវដឹកនាំដោយផ្ទាល់រាល់សកម្មភាពសហប្រតិបត្តិការជាមួយបណ្តាប្រទេសបត្តលេខី ឬភ្នាក់ងារអន្តរជាតិនានា ដែលជាម្ចាស់ជំនួយ សម្រាប់ការអនុវត្តវិធានការឆ្លើយតបបន្ទាន់។

**មាត្រា៥៦.-**

ប្រធាន **គ.ជ.ជ.ស.** ត្រូវជូនដំណឹងភ្លាមទៅសមាជិក **គ.ជ.ជ.ស.** ទាំងអស់ ហើយត្រូវកោះប្រជុំជាបន្ទាន់ ដើម្បីចាត់វិធានការឆ្លើយតប នៅពេលដែលបានទទួលរបាយការណ៍ស្តីពីហេតុការណ៍ដោយចៃដន្យ ដូចមានចែងក្នុងមាត្រា៥៥ ខាងលើ។

## ជំពូកទី៩
## ការផ្តល់ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន

**មាត្រា៥៧.-**

ក្រសួងបរិស្ថានដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវលើកកម្ពស់ការយល់ដឹងនិងការអប់រំចំពោះសាធារណជន ជាពិសេសចំពោះអ្នកដែលធ្វើសកម្មភាព និងប្រតិបត្តិការទាក់ទងនឹងបច្ចេកវិទ្យាជីវសុវត្ថិភាព

តាមរយៈការផ្សព្វផ្សាយច្បាប់ស្តីពីជីវសុវត្ថិភាព និងបទប្បញ្ញត្តិទាំងឡាយដែលសម្រាប់អនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព ។

**មាត្រា៥៨._**

ក្រសួងបរិស្ថាន ត្រូវផ្សព្វផ្សាយព័ត៌មានស្តីពីការនាំចូលសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ ឬដើម្បីបញ្ចូលដោយចេតនាទៅក្នុងបរិស្ថាន និង/ឬដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ឬចំណីសត្វ ឬដើម្បីកែច្នៃ ។

**មាត្រា៥៩._**

ក្រសួងបរិស្ថាន ត្រូវបើកទូលាយឱ្យសាធារណជនបានដឹងពីពាក្យស្នើសុំណាមួយ ដែលពុំត្រូវបានចាត់ទុកថាជាព័ត៌មានសម្ងាត់ ដូចមានចែងក្នុងមាត្រា២៥ នៃច្បាប់ស្តីពីជីវសុវត្ថិភាព ។

**មាត្រា៦០._**

ជនណាក៏ដោយអាចដាក់ជូនក្រសួងបរិស្ថាន នូវយោបល់ជាលាយលក្ខណ៍អក្សរទៅលើសំណើនាំចូល នាំចេញ ផលិតក្នុងស្រុកដែលទាក់ទងនឹងបញ្ហាសារពាង្គកាយកែច្នៃរស់ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតពីថ្ងៃដែលក្រសួងបរិស្ថានធ្វើការផ្សព្វផ្សាយ ។ យោបល់ទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកមួយសម្រាប់ធ្វើការពិចារណាក្នុងការធ្វើសេចក្តីសម្រេច ។ យោបល់ ឬអត្ថាធិប្បាយដែលក្រសួងបរិស្ថានទទួលបាន ព្រមទាំងចម្លើយរបស់ក្រសួងត្រូវបើកទូលាយឱ្យសាធារណជនបានដឹង ។

## ជំពូកទី១០

## ប្រភពធនធាន

**មាត្រា៦១._**

**គ.ជ.ជ.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងបរិស្ថាន ។

**គ.ជ.ជ.ស.** អាចមានសិទ្ធិទទួលមូលនិធិ និងហិរញ្ញប្បទាន ដែលបានមកពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី១១

## ទណ្ឌកម្ម

**មាត្រា៦២.-**

ការប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះ ត្រូវបានផ្តន្ទាទោសទៅតាមទោសប្បញ្ញត្តិនៃច្បាប់ស្តីពីជីវសុវត្ថិភាព ព្រមទាំងច្បាប់និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦៣.-**

ទណ្ឌកម្មរដ្ឋបាល ដែលត្រូវយកមកអនុវត្តសម្រាប់ការប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មានដូចតទៅ ៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាក ឬដកហូតជាបណ្តោះអាសន្ននូវលិខិតឯកភាពជាមុន របស់ក្រសួងបរិស្ថាន
- ការដកហូតជាស្ថាពរនូវលិខិតឯកភាពជាមុន របស់ក្រសួងបរិស្ថាន។

នីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី១២

## អន្តរប្បញ្ញត្តិ

**មាត្រា៦៤.-**

ក្នុងរយៈពេល៦(ប្រាំមួយ)ខែ ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបាន និង/ឬកំពុងធ្វើសកម្មភាព ឬប្រតិបត្តិការទាក់ទងនឹងសកម្មភាពផលិត ដាំដុះ ចិញ្ចឹមសារពាង្គកាយកែច្នៃរស់ ត្រូវធ្វើរបាយការណ៍ព្រមទាំងផ្តល់ឯកសារផ្សេងៗដែលពាក់ព័ន្ធមក **គ.ជ.ជ.ស.** ដើម្បីធ្វើការវាយតម្លៃហានិភ័យ និងដាក់ចេញនូវវិធានការគ្រប់គ្រងហានិភ័យ។

## ជំពូកទី១៣

## អវសានប្បញ្ញត្តិ

**មាត្រា៦៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ៨៧អនក្រ.បកចុះថ្ងៃទី២២..ខែ.មិថុនា.ឆ្នាំ២០១០

ស្តីពី

## យន្តការ និងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព
## ព័ត៌មានចាំបាច់ដែលត្រូវបំពេញនៅក្នុងពាក្យស្នើសុំ
## សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ សារពាង្គកាយកែច្នៃរស់នៅក្នុងបរិស្ថាន

១. ឈ្មោះ អាស័យដ្ឋាន និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់អ្នកនាំចេញ ។

២. ឈ្មោះ អាស័យដ្ឋាន និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់អ្នកនាំចូល ។

៣. ឈ្មោះ និងអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់ ព្រមទាំងចំណាត់ថ្នាក់ក្នុងស្រុក នៃស្ថានភាពជីវសុវត្ថិភាព របស់សារពាង្គកាយកែច្នៃរស់នៅក្នុងប្រទេសនាំចេញប្រសិនបើមាន ។

៤. កាលបរិច្ឆេទគ្រោងទុក ឬកាលបរិច្ឆេទនៃចលនាឆ្លងដែនប្រសិនបើមាន ។

៥. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងប្រមូល ឬទីកន្លែងទទួល និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេទាក់ទងនឹងជីវសុវត្ថិភាព ។

៦. ប្រភព និងមណ្ឌលនៃសេនេទិកចម្រុះរបស់សារពាង្គកាយទទួលយក និង/ឬ សារពាង្គកាយមេ ប្រសិនបើដឹង និងការពិពណ៌នាពីដែនជម្រកដែលសារពាង្គកាយនេះអាចរស់នៅ ឬបង្កើតកូនចៅ ។

៧. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងប្រមូល ឬទីកន្លែងទទួល និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយផ្តល់ឱ្យ ឬសារពាង្គកាយទាក់ទងទៅនឹងជីវសុវត្ថិភាព ។

៨. ការពិពណ៌ពីអាស៊ីតនុយក្លេអ៊ិច ឬការផ្លាស់ប្តូរ ដែលត្រូវបញ្ចូលបច្ចេកវិទ្យាបានប្រើប្រាស់ និងបុគ្គលិកលក្ខណៈដែលជាលទ្ធផលបានមកនៃសារពាង្គកាយកែច្នៃរស់ ។

៩. ការប្រើប្រាស់ដោយចេតនានៃសារពាង្គកាយកែច្នៃរស់ ឬផលិតផលដូចជា សម្ភារៈដែលកែច្នៃរួច ដែលទទួលបានពីសារពាង្គកាយកែច្នៃរស់ ដែលមានផ្ទុកនូវធាតុផ្សំនៃសម្ភារៈសេនេទិក ទទួលបានតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ។

១០. បរិមាណ ឬទំហំនៃសារពាង្គកាយកែច្នៃរស់ដែលនឹងត្រូវបំលែង ។

១១. របាយការណ៍នៃការវាយតម្លៃហានិភ័យពីលើកមុន និងរបាយការណ៍នៃការវាយតម្លៃហានិភ័យបច្ចុប្បន្ន ដែលស្របទៅតាមឧបសម្ព័ន្ធទី៣ ។

១២. វិធីសាស្ត្រដែលបានស្នើសម្រាប់គ្រប់គ្រង ការរក្សាទុក ការផ្ទេរ ការដឹកជញ្ជូន និងការប្រើប្រាស់ ដោយសុវត្ថិភាព រួមបញ្ចូលវិធីសាស្ត្រវេចខ្ចប់ បិទស្លាកសញ្ញា ចែកចាយ យកទៅចោល និងនីតិវិធី គ្រាមានអាសន្នអោយសមស្រប ។

១៣. ស្ថានភាពច្បាប់នៃសារពាង្គកាយកែច្នៃរស់នៅក្នុងប្រទេសនាំចេញ (ឧទាហរណ៍ ប្រសិនបើមានការហាមឃាត់នៅក្នុងប្រទេសដែលនាំចេញនោះ ឬ មានការដាក់កំហិតផ្សេងទៀត ឬក៏មានការឯកភាពចំពោះការឱ្យបញ្ចេញសាយភាយជាទូទៅ) ហើយប្រសិនបើសារពាង្គកាយកែច្នៃរស់ត្រូវបានហាមឃាត់នៅក្នុងប្រទេសនាំចេញ ត្រូវបញ្ជាក់ពីមូលហេតុសម្រាប់ការហាមឃាត់នោះ ។

១៤. លទ្ធផល និងគោលបំណងនៃសេចក្តីជូនព័ត៌មានដោយអ្នកនាំចេញទៅប្រទេសផ្សេងទៀត ស្តីពីសារពាង្គ-កាយកែច្នៃរស់ដែលនឹងត្រូវផ្ទេរ ឬដឹកចេញ ។

១៥. ការបញ្ជាក់ថាព័ត៌មានខាងលើពិតជាត្រឹមត្រូវ ។

## ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ៥៨៧អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០

## ស្តីពី

# យន្តការ និងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព
## ព័ត៌មានចាំបាច់ទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់
## សម្រាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សម្រាប់កែច្នៃ

១. ឈ្មោះ និងព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង របស់អ្នកដាក់ពាក្យសុំ។

២. ឈ្មោះ និងអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់។

៣. ការពិពណ៌នាពីការផ្លាស់ប្តូរសែន បច្ចេកទេសដែលបានប្រើប្រាស់ និងបុគ្គលិកលក្ខណៈទទួលបានពីសារពាង្គកាយកែច្នៃរស់។

៤. អត្តសញ្ញាណកម្មពិសេសនៃសារពាង្គកាយកែច្នៃរស់។

៥. ស្ថានភាពនៃការកំណត់ពូជ ឈ្មោះធម្មតា ទីកន្លែងប្រមូល ឬទីកន្លែងទទួល និងបុគ្គលិកលក្ខណៈ នៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេទាក់ទងទៅនឹងជីវសុវត្ថិភាព។

៦. ប្រភពដើមកំណើត និងមណ្ឌលសេនេទិកនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ ប្រសិនបើស្គាល់ និងការពណ៌នាពីដែនជម្រកដែលសារពាង្គកាយនេះអាចរស់នៅ ឬបង្កើតកូនចៅ។

៧. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងប្រមូល ឬទីកន្លែងទទួល និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយផ្តល់ឱ្យឬសារពាង្គកាយ ទាក់ទងទៅនឹងជីវសុវត្ថិភាព។

៨. ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ដែលបានឯកភាព។

៩. របាយការណ៍វាយតម្លៃពីហានិភ័យ ដែលស្របទៅនឹងឧបសម្ព័ន្ធទី៣។

១០. វិធីសាស្ត្រដែលស្នើឡើងសម្រាប់ការគ្រប់គ្រង ការថែរក្សា ការដឹកជញ្ជូន និងការប្រើប្រាស់ឱ្យមានសុវត្ថិភាព រួមទាំងវិធីសាស្ត្រវេចខ្ចប់ ដាក់ស្លាកសញ្ញា ឯកសារ ការយកទៅចោល និង និងនីតិវិធី គ្រាមានអាសន្ន ឱ្យសមស្រប។

## ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០១០

## ស្តីពី

## យន្តការ និងនីតិវិធីអនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាព
## ការវាយតម្លៃហានិភ័យ

### គោលបំណង

១. គោលបំណងនៃការវាយតម្លៃហានិភ័យនៅក្នុងពិធីសារកាតាហេ្សណា គឺដើម្បីធ្វើអត្តសញ្ញាណ និងវាយតម្លៃហេតុប៉ះពាល់ធ្ងន់ធ្ងរនៃសារពាង្គកាយកែច្នៃរស់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព នៃជីវៈចម្រុះនៅក្នុងបរិស្ថាន ដែលអាចនឹងទទួលផលប៉ះពាល់ខ្លាំង ព្រមទាំងគិតគូរផងដែរពីហានិភ័យទាំងឡាយដល់សុខភាពមនុស្ស ។

### ការប្រើប្រាស់ការវាយតម្លៃហានិភ័យ

២. ការវាយតម្លៃហានិភ័យដែលត្រូវបានអនុវត្តដោយក្រសួងបរិស្ថានដើម្បីធ្វើសេចក្តីសម្រេចលើបញ្ហាសារពាង្គកាយកែច្នៃរស់ ។

### គោលការណ៍ទូទៅ

៣. ការវាយតម្លៃហានិភ័យត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ និងមានតម្លាភាពហើយត្រូវយកចិត្តទុកដាក់ចំពោះយោបល់របស់អ្នកឯកទេស និងគោលការណ៍ណែនាំដែលរៀបចំឡើង ដោយអង្គការអន្តរជាតិពាក់ព័ន្ធ ។

៤. ការខ្វះខាតចំណេះដឹងខាងវិទ្យាសាស្ត្រ ឬការឯកភាពផ្នែកវិទ្យាសាស្ត្រមិនមែន ជាការចាំបាច់ក្នុងការបកស្រាយ ដូចជាការបង្ហាញពីកម្រិតជាក់ស្តែងណាមួយនៃហានិភ័យ ឬអវត្តមាននៃហានិភ័យ ឬហានិភ័យនោះអាចទទួលយកបានជាដើម ។

៥. ហានិភ័យដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ឬផលិតផលសារពាង្គកាយកែច្នៃរស់ ដែលជារួមមានផលិតផលកែច្នៃពីសារពាង្គកាយកែច្នៃរស់ដែលជាប្រភពដើម ហើយផ្ទុកនូវធាតុផ្សំដែលរកឃើញថ្មីៗ នៃសម្ភារៈសេនេទិកទទួលបានតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ត្រូវតែគិតគូរនៅក្នុងបរិបទនៃ ហានិភ័យដែលបង្កឡើងដោយសារពាង្គកាយមិនទទួលយក ឬសារពាង្គកាយមេនៅក្នុងបរិស្ថាន ដែលនឹងអាចទទួលផលប៉ះពាល់ខ្លាំង ។

៦. ការវាយតម្លៃហានិភ័យ ត្រូវអនុវត្តឈរលើមូលដ្ឋានមួយករណីម្តងតាមស្ថានភាពជាក់ស្តែង ។ ព័ត៌មាន ដែលត្រូវការចាំបាច់អាចប្រែប្រួលទៅតាមលក្ខណៈធម្មជាតិ និងកម្រិតលម្អិតពីករណីមួយទៅករណីមួយទៀត អាស្រ័យទៅលើសារពាង្គកាយកែច្នៃរស់ពាក់ព័ន្ធ គោលដៅនៃការប្រើប្រាស់ និងបរិស្ថានដែលអាចនឹងទទួលរងផលប៉ះពាល់ខ្លាំង ។

## វិធីសាស្ត្រ

៧. ដំណើរការនៃការវាយតម្លៃហានិភ័យអាចត្រូវការព័ត៌មានបន្ថែមអំពី ប្រធានបទវិទ្យាសាស្ត្រជាក់លាក់ដែលត្រូវបានកំណត់ និងស្នើឡើងក្នុងដំណើរការវាយតម្លៃនេះ។ ចំណែកឯព័ត៌មានអំពីប្រធានបទផ្សេងទៀតអាចមិនពាក់ព័ន្ធនៅក្នុងករណីមួយចំនួនឡើយ ។

៨. ដើម្បីបំពេញគោលបំណងនេះការវាយតម្លៃហានិភ័យទាមទារនូវជំហានសមស្របដូចខាងក្រោមនេះ ÷

ក. អត្តសញ្ញាណកម្មនៃលក្ខណៈសេណូទីប (Genotypic) និងផេណូទីប (Phenotypic) ភ្ជាប់ជាមួយនឹងសារពាង្គកាយកែច្នៃរស់ ដែលអាចមានឥទ្ធិពលអវិជ្ជមានទៅលើជីវៈចម្រុះ នៅក្នុងបរិស្ថាន ដែលអាចនឹងទទួលផលប៉ះពាល់ខ្លាំងព្រមទាំងហានិភ័យដល់សុខភាពមនុស្ស ។

ខ. ការវាយតម្លៃពីលទ្ធភាព (Likelihood) ដែលអាចកើតមានហានិភ័យអវិជ្ជមានទាំងនេះត្រូវបានយកចិត្តទុកដាក់ ដោយគិតគូរពីកម្រិតសាយភាយ និងបរិស្ថាន ដែលអាចទទួលផលប៉ះពាល់ខ្លាំងពីសារពាង្គកាយកែច្នៃរស់ ។

គ. យកចិត្តទុកដាក់អំពីការវាយតម្លៃលើផលវិបាកដែលអាចមានផលប៉ះពាល់អវិជ្ជមាន។

ឃ. ការប៉ាន់ស្មាននៃហានិភ័យទាំងមូល ដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃពីលទ្ធភាពដែលអាចកើតមាននូវផលប៉ះពាល់អវិជ្ជមាន។

ង. អនុសាសន៍ថា តើហានិភ័យនេះអាចទទួលយកបានឬអាចគ្រប់គ្រងបានដែរឬទេ រួមទាំងការកំណត់ពីយុទ្ធសាស្ត្រចាំបាច់ដើម្បីគ្រប់គ្រងហានិភ័យទាំងនេះ។

ច. នៅពេលមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងកម្រិតហានិភ័យ ត្រូវស្នើសុំព័ត៌មានបន្ថែមពីបញ្ហាជាក់ស្តែង ឬដោយអនុវត្តនូវយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ឬដោយតាមដានត្រួតពិនិត្យសារពាង្គកាយកែច្នៃរស់ នៅក្នុងបរិស្ថាន ។

**ចំណុចដែលត្រូវលើកយកមកពិចារណា**

៩. ផ្អែកទៅលើករណីនេះ ការវាយតម្លៃហានិភ័យត្រូវគិតគូរដល់សេចក្តីលម្អិតនៃបច្ចេកទេស និងវិទ្យាសាស្ត្រពាក់ព័ន្ធនឹងបុគ្គលិកលក្ខណៈនៃប្រធានបទខាងក្រោម ÷

ក. *សារពាង្គកាយទទួលយក ឬសារពាង្គកាយមេ* : លក្ខណៈជីវសាស្ត្រនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេរួមមាន ព័ត៌មានស្តីពីស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ដើមកំណើត ប្រភពដើមកំណើត និងមជ្ឈមណ្ឌលសេនេទិកចម្រុះប្រសិនជាដឹង និងការពិពណ៌នា ពីដែនជំរកនៃសារពាង្គកាយទាំងនោះ អាចធន់ ឬកកើតសាយភាយបាន ។

ខ. *សារពាង្គកាយផ្តល់ឱ្យ* : ស្ថានភាពនៃការកំណត់ពូជអំបូរ និងឈ្មោះធម្មតា ប្រភព និងបុគ្គលិកលក្ខណៈជីវសាស្ត្រពាក់ព័ន្ធនៃសារពាង្គកាយផ្តល់ឱ្យ ។

គ. *ភ្នាក់ងារចំលង ( Vector )* : បុគ្គលិកលក្ខណៈនៃភ្នាក់ងារចំលង (បើមាន) ដែលរួមមានប្រភពដើមកំណើត និងទំហំនៃដែនជម្រក ។

ឃ. *ការបញ្ចូល ឬ/និងបុគ្គលិកលក្ខណៈនៃការកែប្រែហ្សែន* : បុគ្គលិកលក្ខណៈសេនេទិកនៃអាស៊ីតនុយក្លេអ៊ិច ដែលត្រូវបានបញ្ចូល ឬ/និងមុខងាររបស់វា និងបុគ្គលិកលក្ខណៈ នៃការកែប្រែហ្សែនត្រូវបានបង្ហាញ ។

ង. *សារពាង្គកាយកែច្នៃរស់* : អត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់ ព្រមទាំងភាពខុសគ្នារវាងលក្ខណៈ ជីវសាស្ត្រនៃសារពាង្គកាយកែច្នៃរស់ និងលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ ។

ច. *ការចាប់វត្តមាន និងការធ្វើអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់* : វិធីសាស្ត្រ នៃការចាប់វត្តមាន និងការធ្វើអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់ និងភាពខុសគ្នារវាងលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយកែច្នៃរស់ និងសារពាង្គកាយទទួលយកទាំងនោះ ឬសារពាង្គកាយមេ ។

ឆ. *ព័ត៌មានទាក់ទងទៅនឹងការប្រើប្រាស់ដោយចេតនា* : ព័ត៌មានទាក់ទងទៅនឹងការប្រើប្រាស់ដោយចេតនានៃសារពាង្គកាយកែច្នៃរស់ រួមមានការប្រើប្រាស់ថ្មី ឬការប្រើប្រាស់ ដែលត្រូវផ្លាស់ប្តូរប្រៀបធៀបទៅនឹងសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ ។

ជ. *បរិស្ថានដែលទទួលយក* : ព័ត៌មានស្តីពីលក្ខណៈអាកាសធាតុ និងភូមិសាស្ត្រ រួមបញ្ចូលព័ត៌មានដែលទាក់ទងនៅលើជីវៈចម្រុះ និងប្រភពដើមកំណើតនៃបរិស្ថាន ដែលអាចនឹងទទួលផលប៉ះពាល់ធ្ងន់ធ្ងរ ។